ក្រសួងបរិស្ថាន

លេខ: ០០៨ /ប្រ.ក .ប.ស្ក

# ប្រកាស
## ស្តីពី
## ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ "ព្រាំងចំការក្រោម" នៃតំបន់ប្រើប្រាស់ច្រើនយ៉ាង ស្ថិតក្នុងភូមិព្រាំង ឃុំដងពែង និងភូមិចំការក្រោម ឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣/ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨/ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំង
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញលិខិតចុះថ្ងៃទី ០២ ខែមករា ឆ្នាំ២០០៩ ស្តីពីការស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ "ព្រាំងចំការក្រោម"
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១._**

ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ "ព្រាំងចំការក្រោម" ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែងស្ថិតនៅភូមិព្រាំង ឃុំដងពែង និងភូមិចំការក្រោម ឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង។

**ប្រការ២._**

សហគមន៍តំបន់ការពារធម្មជាតិ«ព្រាំងចំការក្រោម» នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងជងពែង មានផ្ទៃដីទំហំ៨៥៩ហិកតា (ប្រាំបីរយហាសិបប្រាំបួនហិកតា) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ និងមាននិយាមកា ( Datum: Indian_1960_UTM_Zone_48N) ដូចខាងក្រោម៖

| ID | Point | X | Y | ID | Point | X | Y |
|---|---|---|---|---|---|---|---|
| 1 | A | ៣៥៥៩៧៧ | ១២៣១៩៥៨ | 12 | L | ៣៥៦៤៤៩ | ១២២៥៩២៦ |
| 2 | B | ៣៥៧៥៩៤ | ១២៣១៧៩៤ | 13 | M | ៣៥៧៥៨៩ | ១២២៧០៤២ |
| 3 | C | ៣៥៨០៨០ | ១២៣០៩១០ | 14 | N | ៣៥៧៥៣២ | ១២២៧១៨០ |
| 4 | D | ៣៥៨២២៥ | ១២៣១០៥៤ | 15 | O | ៣៥៧៧៤៩ | ១២២៧៣៨៩ |
| 5 | E | ៣៥៧៩០២ | ១២៣២០៥៤ | 16 | P | ៣៥៧៩៩៥ | ១២២៧៧៥៧ |
| 6 | F | ៣៥៦៥០១ | ១២៣២៥៤៤ | 17 | Q | ៣៥៨៨០២ | ១២២៨៣៣៦ |
| 7 | G | ៣៥៦៦២៩ | ១២២៩២១៥ | 18 | R | ៣៥៨៨០២ | ១២២៩០៩៥ |
| 8 | H | ៣៥៦៤៦៣ | ១២២៨១៨៤ | 19 | S | ៣៥៩២០៧ | ១២២៩៦១០ |
| 9 | I | ៣៥៥២៦៣ | ១២២៨០៥៣ | 20 | T | ៣៥៨៥៥៣ | ១២២៩៦៨៦ |
| 10 | J | ៣៥៤០៥៧ | ១២២៧៦៦៩ | 21 | U | ៣៥៨២៩២ | ១២២៩៤៩២ |
| 11 | K | ៣៥៦០១១ | ១២២៦២២៦ | 22 | V | ៣៥៧៨៣៣ | ១២៣០០៨១ |

**ប្រការ៣._**

ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ «ព្រាំងចំការក្រោម» ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤._**

សហគមន៍តំបន់ការពារធម្មជាតិ «ព្រាំងចំការក្រោម» ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងជងពែងត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ សហគមន៍តំបន់ការពារធម្មជាតិ «ព្រាំងចំការក្រោម» ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ការពារ និងអភិរក្សធម្មជាតិ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តកោះកុង នាយកតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង និងសហគមន៍តំបន់ការពារធម្មជាតិ «ព្រាំងចំការក្រោម» ត្រូវអនុវត្តន៍ប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧

រដ្ឋមន្ត្រី

សាយ សំអាល់

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តកោះកុង
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ
- កាលប្បវត្តិ

បួឆ-សីហា